ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**<u>កិច្ចព្រមព្រៀង ស្តីពីការព្យួរកិច្ចសន្យាការងារនិយោជិតជនបរទេស</u>**

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៨និង០០នាទីព្រឹក នៅក្នុងរោងចក្រផលិតស្បែកជើង ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី បានចុះកិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារជាមួយនិយោជិតជនបរទេសប្រចាំរោងចក្រផលិតស្បែកជើង ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី ដែលមានប្រការដូចខាងក្រោម៖

**ប្រការ១៖** ព្យួរកិច្ចសន្យាការងារនិយោជិតជនបរទេសចំនួន ១០នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន **៧៣៨នា** រយៈពេល **៤២ថ្ងៃគិតចាប់ពីថ្ងៃទី២០ ខែកក្កដា ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០** ដោយមូលហេតុគ្មានការបញ្ជាទិញ។

**ប្រការ២៖** ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូននិយោជិតជនបរទេសម្នាក់ៗចំនួន **១០០ដុល្លារអាមេរិកក្នុង១ខែ** ក្នុងនោះ៖

-ចំនួន ៣៥ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ

-ចំនួន ៧០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ

-ចំនួន ១០០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ

ដោយព្រមព្រៀងបើករៀងរាល់ថ្ងៃទី១០។

ខេត្តតាកែវ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

តំណាងភាគីនិយោជិតជនបរទេស

MR. LUO YONG GUI

តំណាងភាគីក្រុមហ៊ុន

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន C.C.F ... CO., LTD. KINGDOM OF CAMBODIA